ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ
-លេខ ៦១៦ "ត"
ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២
-សំណុំរឿងព្រហ្មទណ្ឌលេខ ២៦៦១
ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១
-ស៊ើបសួរលេខ ១៩៧០
ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១
-ជំនុំជម្រះលេខ ៤៥៥១
ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១

តាចនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោង ១៤ រសៀល នៅសាលសវនាការទី២ ដោយមានសមាសភាព៖

ចៅក្រមជំនុំជម្រះ

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

-ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ២៦៦១ ចុះថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ ឈ្មោះ [redacted] មកពី ភេទប្រុស អាយុ ៣៦ឆ្នាំ ជនជាតិខ្មែរ មុខរបរម៉ៅការសំណង់ សាសនា ព្រះពុទ្ធ ទីកន្លែងកំណើតភូមិ [redacted] ខេត្តកំពង់ស្ពឺ ទីលំនៅមុនពេលឃុំខ្លួនស្នាក់នៅផ្ទះជួល ផ្លូវលេខ២២០ សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ [redacted] ស្រីលក្ខ មានកូន ៣នាក់ ឪពុកឈ្មោះ [redacted] យ៉ាន "ស្លាប់" ម្តាយឈ្មោះ [redacted] សឿន "ស្លាប់" ជានីតិជន ទោសពីមុន គ្មាន ។

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៤៧៨៧ "ជ១"ដ.ឃ.ដ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១ ។

ជាប់ចោទពីបទ **រំលោភលើចំនុកចិត្តពិសេសដោយអភិបាល** ប្រព្រឹត្តនៅក្រុមហ៊ុន អ៊ីមស៊ី លីហ្សិន&សីលូសិន ស្ថិតនៅអគារប្រផេះលេខ២៤៧ ជាន់ផ្ទាល់ដី បន្ទប់លេខ០៦៦ អគារខាងត្បូងE ភូមិ១ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០២០ ដល់ខែមករា ឆ្នាំ២០២១ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៩១ មាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ ។

-មានលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] Toyoshi ភេទប្រុស ជនជាតិជប៉ុន កាន់លិខិតឆ្លងដែនលេខ TS5351844 ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២០ ជាប្រធានក្រុមប្រឹក្សាភិបាល ស្នាក់នៅសាខាក្រុមហ៊ុនអ៊ីមស៊ីលីហ្សិន & សីលូសិន នៅអគារប្រផេះលេខ២៤៧ ជាន់ផ្ទាល់ដី បន្ទប់លេខ០៦៦ អគារខាងត្បូងE ភូមិ១ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

-មានមេធាវី [redacted] ជាមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី ។

អង្គហេតុនៃរឿងអាទិភាពជាដើម

កាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩ ឈ្មោះ [redacted] មកពី បានចូលបម្រើការងារនៅក្នុងក្រុមហ៊ុន អ៊ីមស៊ីលីហ្សិន & សីលូសិន មានទីតាំងស្ថិតនៅអគារប្រផេះលេខ២៤៧ ជាន់ផ្ទាល់ដី បន្ទប់លេខ០៦៦ អគារខាងត្បូងE ភូមិ១ សង្កាត់ទន្លេបា

សាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ មានតួនាទីអ្នកផ្តត់ផ្តង់ជណ្តើរយន្តរបស់ក្រុមហ៊ុនខាងលើទៅឱ្យអតិថិជន និងប្រមូលប្រាក់ពីអតិថិជនយកមកប្រគល់ឱ្យក្រុមហ៊ុនវិញ ដោយទទួលបានប្រាក់ខែ ៦៣០ ដុល្លារអាមេរិក ក្នុងមួយខែ (ប្រាំមួយរយ សាមសិប) ដុល្លារអាមេរិក ។ លុះមកដល់អំឡុងឆ្នាំ២០២០ ដល់ខែមករា ឆ្នាំ២០២១ ឈ្មោះ [redacted] មករា ក៏ចាប់ផ្តើមមានចេតនាទុច្ចរិតកែបំបាត់ប្រាក់របស់ក្រុមហ៊ុន ដែលបានមកពីការលក់ជណ្តើរយន្តសរុប ៥៣.៧៣០ ដុល្លារអាមេរិក (ប្រាំម៉ឺន បីពាន់ ប្រាំពីររយ សាមសិប) ដុល្លារអាមេរិក ។ ជនជាប់ចោទខាងលើបានប្រើល្បិចឱ្យអតិថិជនមួយចំនួន ដែលបានទិញជណ្តើរយន្តពីក្រុមហ៊ុន ទូទាត់ប្រាក់ចេញមូលប្បទានបត្រដាក់ឈ្មោះ [redacted] មករា ឬ ផ្ទេរប្រាក់ចូលគណនេយ្យរបស់ឈ្មោះ [redacted] មករា តែម្តង ហើយឈ្មោះនេះបានដកប្រាក់ទាំងនោះទៅប្រើប្រាស់ផ្ទាល់ខ្លួន ដោយមិនប្រគល់ឱ្យក្រុមហ៊ុននោះទេ ។ ក្រោយមកក្រុមហ៊ុនមានការសង្ស័យក៏បានធ្វើការពិនិត្យ ហើយឈ្មោះ [redacted] មករា បានធ្លើយសារភាពដែរថា ខ្លួនពិតជាបានក៏បកេងយកប្រាក់របស់ក្រុមហ៊ុនអស់ចំនួនដូចខាងលើពិតប្រាកដមែន ។

- បានឃើញ របាយការណ៍សំយោគលេខ ១៨៦/២១ រ.ប.ក ចុះថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០២១ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតស្រាល នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ។
- បានឃើញ កំណត់ហេតុស្តីពីការសួរចម្លើយជនត្រូវចោទឈ្មោះ [redacted] មករា ចុះថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ ។
- បានឃើញ កំណត់ហេតុស្តីពីការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីតំណាងដោយមេធាវី [redacted] ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០២១ របសចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ ។
- បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ២០៣៥ អ.ឃ.ធ ចុះថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។
- បានឃើញ ដីកាសន្និដ្ឋានស្តាពរលេខ ៤១៣៥ អ.ឃ.ធ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។
- បានឃើញ ដីកាសម្រេចរក្សាជនត្រូវចោទឱ្យនៅជាប់ឃុំបណ្តោះអាសន្នលេខ ៨៦៨៣ "ជ" ដ.ឃ.ដ ចុះថ្ងៃទី ០២ ខែធ្នូ ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ ។
- បានឃើញ ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ៥៦៣១ "ជ១"ដ.ដ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] មករា បានធ្លើយថា៖ ខ្លួនជាបុគ្គលិកក្រុមហ៊ុនអ៊ីមស៊ីលីហ្វ&សីលូសិន មានតួនាទីជាអ្នកប្រតិបត្តិការលក់ជណ្តើរយន្តរបស់ក្រុមហ៊ុនឱ្យទៅអតិថិជន និងប្រមូលប្រាក់ពីអតិថិជនយកមកប្រគល់ឱ្យក្រុមហ៊ុនវិញប្រាកដមែន ។ ខ្លួនពិតជាបានទទួលប្រាក់ពីអតិថិជនរួចហើយ ពុំបានយកប្រាក់ទាំងអស់នោះមកប្រគល់ឱ្យក្រុមហ៊ុនប្រាកដមែន ដោយទុកជាប្រយោជន៍ផ្ទាល់ខ្លួន ។ ប្រាក់ដែលខ្លួនយកពីអតិតិជនមកគឺខ្លួនប្រើប្រាស់ដោះស្រាយជីវភាពផ្ទាល់ខ្លួនសរុបទាំងអស់ចំនួន ៥៣.៧៣០ ដុល្លារអាមេរិក (ប្រាំម៉ឺន បីពាន់ ប្រាំពីររយ សាមសិប) ដុល្លារអាមេរិក ។ ខ្លួនបានដឹងកំហុសហើយខ្លួនសុំសងប្រាក់ទៅក្រុមហ៊ុនវិញតាមលទ្ធភាព ។

-មេធាវី [redacted] ជាមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្លើយថា ឈ្មោះ [redacted] មករា ជាបុគ្គលិកក្រុមហ៊ុន អ៊ីមស៊ីលីហ្វ & សីលូសិន មានតួនាទីជាអ្នកប្រតិបត្តិការលក់ជណ្តើរយន្តរបស់ក្រុមហ៊ុនឱ្យទៅអតិថិជន និងប្រមូលប្រាក់ពីអតិថិជនយកមកប្រគល់ឱ្យក្រុមហ៊ុនវិញ ។ ប៉ុន្តែឈ្មោះ [redacted] មករា មានចេតនាទុច្ចរិត

កែបំបាត់ប្រាក់របស់ក្រុមហ៊ុន ដោយឈ្មោះនេះបានប្រើល្បិចឱ្យអតិថិជនទូទាត់ប្រាក់មកឱ្យក្រុមហ៊ុនដោយចេញមូលប្បទាន-បត្រដាក់ឈ្មោះ [redacted] មកវា ផ្ទាល់ និងមានពេលខ្លះឱ្យបាញ់ប្រាក់ចូលគណនីរបស់ឈ្មោះ [redacted] មកវា ផ្ទាល់ ។ បន្ទាប់ពីបានទទួលប្រាក់ពីអតិថិជនរួចហើយ ឈ្មោះ [redacted] មកវា ពុំបានយកប្រាក់ទាំងនោះមកប្រគល់ឱ្យក្រុមហ៊ុននោះទេ ដោយទុកជាប្រយោជន៍ផ្ទាល់ខ្លួន សរុបប្រាក់ទាំងអស់ចំនួន ៥៣.៧៣០ ដុល្លារ (ប្រាំម៉ឺន បីពាន់ ប្រាំពីររយ សាមសិប) ដុល្លារអាមេរិក ។

សេចក្តីសន្និដ្ឋានរបស់មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី

-លោកស្រី [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា ឈ្មោះ [redacted] មកវា ជាបុគ្គលិកក្រុមហ៊ុន អ៊ីមស៊ីលីហ្វ & សឺលូសិន មានតួនាទីជាអ្នកប្រតិបត្តិការលក់ជណ្តើរយន្តរបស់ក្រុមហ៊ុនឱ្យទៅអតិថិជន និងប្រមូលប្រាក់ពីអតិថិជនយកមកប្រគល់ឱ្យក្រុមហ៊ុនវិញ ។ ប៉ុន្តែឈ្មោះ [redacted] មកវា មានចេតនាទុច្ចរិតកែបំបាត់ប្រាក់របស់ក្រុមហ៊ុនដែលអតិថិជនមូមាត់មកឱ្យក្រុមហ៊ុន យកមកជាប្រយោជន៍ផ្ទាល់ខ្លួន សរុបប្រាក់ទាំងរស់ចំនួន ៥៣.៧៣០ ដុល្លារអាមេរិក (ប្រាំម៉ឺន បីពាន់ ប្រាំពីររយ សាមសិប) ដុល្លារអាមេរិក ។ សំណូមពរសុំឱ្យផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ សុំឱ្យជនជាប់ចោទសងប្រាក់ចំនួន ៥៣.៧៣០ ដុល្លារអាមេរិក (ប្រាំម៉ឺន បីពាន់ប្រាំពីររយសាមសិប) ដុល្លារអាមេរិក និងទាមទារសំណងសេវាកម្មច្បាប់ និងជំងឺចិត្តចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក ។

សេចក្តីសន្និដ្ឋានបិទសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថាក្រោយពីសាកសួរនាពេលសវនាការនេះឃើញថា ជនជាប់ចោទបានធ្វើយសារភាពអស់ហើយនូវអំពើប្រព្រឹត្តរបស់ខ្លួន ដែលស៊ីសង្វាក់ទៅនឹងចម្លើយរបស់មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី និងភស្តុតាងក្នុងសំណុំរឿង ។ **អំពើប្រព្រឹត្តរបស់ជនជាប់ចោទជាបទល្មើស រំលោភលើទំនុកចិត្តពិសេសដោយអភិបាល** បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៩១ មាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ ។ តំណាងអយ្យការសុំតម្កល់ការចោទប្រកាន់លើជនជាប់ចោទ តាមដីកាសន្និដ្ឋានស្តាពរលេខ ៤១៣៥ អ.យ.ធ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២១ ដដែល និងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] មកវា សំណូមពរចុងក្រោយ ខ្លួនបានដឹងនូវកំហុសហើយ សុំឱ្យតុលាការជួយបន្ធូបន្ថយទោស ដើម្បីនាប់បានចេញពីពន្ធនាគារទៅរកប្រាក់យកមកសងក្រុមហ៊ុនវិញ ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមផ្លូវច្បាប់ហើយ

<u>សំអាងហេតុ</u>

១-កាលអំឡុងឆ្នាំ២០២០ ដល់ខែមករា ឆ្នាំ២០២១ ពិតជាមានអង្គហេតុ**រំលោភលើទំនុកចិត្តពិសេសដោយអភិបាល** នៅក្រុមហ៊ុនអ៊ីមស៊ីលីហ្វ & សឺលូសិន ស្ថិតនៅអគារប្រផេះលេខ២៤៧ ជាន់ផ្ទាល់ដី បន្ទប់លេខ០៦៦ អគារខាងត្បូងE ភូមិ១ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ខណៈពេលដែលជនជាប់ចោទឈ្មោះ [redacted] មកវា ជាបុគ្គលិកក្រុមហ៊ុនអ៊ីមស៊ីលីហ្វ & សឺលូសិន មានតួនាទីជាអ្នកប្រតិបត្តិការលក់ជណ្តើរយន្តរបស់ក្រុមហ៊ុនឱ្យទៅអតិថិជន និងប្រមូលប្រាក់ពី

អតិថិជនយកមកប្រគល់ឱ្យក្រុមហ៊ុនវិញ ។ ប៉ុន្តែឈ្មោះ [redacted] មករា មានចេតនាទុច្ចរិតកែបំបាត់ប្រាក់របស់ក្រុមហ៊ុន ដោយប្រើល្បិចឱ្យអតិថិជនទូទាត់ប្រាក់តាមមូលប្បទានប័ត្រដាក់ឈ្មោះខ្លួន និងឱ្យផ្ទេរប្រាក់ចូលគណនីរបស់ខ្លួន សរុបប្រាក់ទាំងអស់ចំនួន ៥៣.៧៣០ ដុល្លារ (ប្រាំម៉ឺន បីពាន់ ប្រាំពីររយ សាមសិប) ដុល្លារអាមេរិក យកទៅប្រើប្រាស់ជាប្រយោជន៍ផ្ទាល់ខ្លួន ប្រាកដមែន ។

២-ផ្អែកតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] មករា បានឆ្លើយសារភាពថា៖ ខ្លួនជាបុគ្គលិកក្រុមហ៊ុន អ៊ីមស៊ីលីហ្វ & សីលូសិន មានតួនាទីជាអ្នកប្រតិបត្តិការលក់ជណ្តើរយន្តរបស់ក្រុមហ៊ុនឱ្យទៅអតិថិជន និងប្រមូលប្រាក់ពីអតិថិជនយកមកប្រគល់ឱ្យក្រុមហ៊ុនវិញ ប៉ុន្តែពេលទទួលប្រាក់ពីអតិថិជនរួចហើយ ខ្លួនមិនប្រគល់ប្រាក់ទៅឱ្យក្រុមហ៊ុនទេ ដោយទុកប្រើប្រាស់ជាប្រយោជន៍ផ្ទាល់ខ្លួន សរុបទាំងអស់ចំនួន **៥៣.៧៣០** ដុល្លារអាមេរិក **(ប្រាំម៉ឺន បីពាន់ ប្រាំពីររយ សាមសិប)** ដុល្លារអាមេរិក ពិតប្រាកដមែន ។ ចម្លើយនេះស៊ីសង្វាក់ទៅនឹងចម្លើយរបស់មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីដែលបញ្ជាក់ថា ឈ្មោះ [redacted] **មករា** ជាបុគ្គលិកក្រុមហ៊ុន មានតួនាទីជាអ្នកប្រតិបត្តិការលក់ជណ្តើរយន្តឱ្យទៅអតិថិជន និងប្រមូលប្រាក់ពីអតិថិជនយកមកប្រគល់ឱ្យក្រុមហ៊ុនវិញ ប៉ុន្តែឈ្មោះ [redacted] **មករា** កែបំបាត់យកប្រាក់របស់ក្រុមហ៊ុន សរុបអស់ចំនួន ៥៣.៧៣០ ដុល្លារ (ប្រាំម៉ឺន បីពាន់ ប្រាំពីររយ សាមសិប) ដុល្លារអាមេរិក ។ **អំពើប្រព្រឹត្តរបស់ជនជាប់ចោទជាបទល្មើស រំលោភលើចំនុកចិត្តពិសេសដោយអភិបាល** មានចែងឱ្យផ្តន្ទាទោសតាមមាត្រា **៣៩១** មាត្រា **៣៩៣** នៃក្រមព្រហ្មទណ្ឌ ។

៣-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ជនជាប់ចោទបានឆ្លើយសារភាពអស់ហើយនូវអំពើប្រព្រឹត្តរបស់ខ្លួនដែលស៊ីសង្វាក់ទៅនឹងចម្លើយរបស់មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី និងភស្តុតាងក្នុងសំណុំរឿង ។ **អំពើប្រព្រឹត្តរបស់ជនជាប់ចោទជាបទល្មើស រំលោភលើចំនុកចិត្តពិសេសដោយអភិបាល** បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣៩១ មាត្រា៣៩៣ នៃក្រមព្រហ្មទណ្ឌ សុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ តុលាការគប្បីពិចារណា ។

៤-ជនជាប់ចោទឈ្មោះ [redacted] មករា ភេទប្រុស អាយុ ៣៦ឆ្នាំ ជនជាតិខ្មែរ ជានីតិជន និងជាសមត្ថជនមានស្មារតីជានាល្អ អាចយល់ដឹងគ្រប់គ្រាន់ពេលប្រព្រឹត្តបទល្មើស (គ្មានវិបល្លាសស្មារតី) ដែលអាចទទួលខុសត្រូវនូវអំពើប្រព្រឹត្តរបស់ខ្លួនបាន ។

៥-មានពិរុទ្ធភាព និងភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ [redacted] មករា ភេទប្រុស អាយុ ៣៦ឆ្នាំ ជនជាតិខ្មែរ ពីបទ **រំលោភលើចំនុកចិត្តពិសេសដោយអភិបាល** ប្រព្រឹត្តនៅក្រុមហ៊ុន អ៊ីមស៊ីលីហ្វ & សីលូសិន ស្ថិតនៅអគារប្រផេះលេខ២៤៧ ជាន់ផ្តាល់ដី បន្ទប់លេខ០៦៦ អគារខាងត្បូងE ភូមិ១ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០២០ ដល់ខែមករា ឆ្នាំ២០២១ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៩១ មាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ ។

៦-មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីទាមទារប្រាក់ដែលឈ្មោះ [redacted] មករា យកចំនួន ៥៣.៧៣០ ដុល្លារអាមេរិក (ប្រាំម៉ឺន បីពាន់ប្រាំពីររយសាមសិប) ដុល្លារអាមេរិក និងទាមទារសំណងសេវាកម្មច្បាប់ និងជំងឺចិត្តចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក តុលាការគប្បីពិចារណា ។

៧-ជនជាប់ចោទឈ្មោះ [redacted] មករា សំណូមពរចុងក្រោយខ្លួនបានដឹងនូវកំហុសហើយ សុំឱ្យតុលាការជួយបន្ថយបន្តយទោស ដើម្បីឆាប់បានចេញពីពន្ធនាគារ ទៅរកប្រាក់យកមកសងក្រុមហ៊ុនវិញ ។ តុលាការយល់ឃើញថាជនជាប់ចោទទើបតែប្រព្រឹត្តបទល្មើសជាលើកទី១ ហើយភ្លាក់រលឹកដឹងនូវកំហុស និងដើម្បីឆាប់បានទៅរកប្រាក់យកមកសងក្រុមហ៊ុនវិញ ដូចនេះតុលាការគប្បីពិចារណាលើកយកស្ថានសម្រាលមកអនុវត្តទៅលើជនជាប់ចោទ ដោយយោងតាមមាត្រា ៨៣,៨៤,១០៧ និងមាត្រា ១០៨ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

ហេតុផ្តេីសេចក្តីសម្រេច

១-ផ្តន្ទាទោសលើឈ្មោះ [redacted] មករា ភេទប្រុស អាយុ ៣៦ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ២ (ពីរ) ឆ្នាំ តែអនុវត្តទោសក្នុងពន្ធនាគាររយៈពេល ១ (មួយ) ឆ្នាំ ទោសសល់ប៉ុន្មានព្យួរធម្មតាទាំងអស់ ពីបទ **រំលោភលើចំនុកចិត្តពិសេសដោយអភិបាល** ប្រព្រឹត្តនៅក្រុមហ៊ុន អ៊ីមស៊ីលីហ្វ & សិលូសិន ស្ថិតនៅអគារប្រផេះលេខ២៤៧ ជាន់ផ្តាល់ដី បន្ទប់លេខ០៦៦ អគារខាងត្បូងE ភូមិ១ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០២០ ដល់ខែមករា ឆ្នាំ២០២១ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៩១ មាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ។

២-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] មករា សងសំណងចំនួន ៥៣.៧៣០ (ប្រាំម៉ឺនបីពាន់ប្រាំពីររយសាមសិប) ដុល្លារសហរដ្ឋអាមេរិក និងជាំងចិត្តចំនួន ១០.០០០.០០០ (ដប់លាន) រៀល ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] Toyoshi តំណាងសាខាក្រុមហ៊ុនអ៊ីមស៊ីលីហ្វ & ស៊ីលូសិន ការទាមទារលើសពីនេះត្រូវបដិសេធចោល ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ និងមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈ:នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ បើកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់ ៕

ក្រឡាបញ្ជីសវនាការ

ហត្ថលេខានិងត្រា [redacted]

ចៅក្រមជំនុំជម្រះ

ហត្ថលេខានិងត្រា [redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ១៣កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០២២

ក្រឡាបញ្ជី

[redacted]

បានឃើញ

ចៅក្រមជំនុំជម្រះ

[redacted]

Scanned with CamScanner